## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

សេចក្តីប្រកាសព័ត៌មាន

### សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
### បានបញ្ចប់ទស្សនកិច្ចនិងការចូលរួមខួបអនុស្សាវរីយ៍លើកទី៨០ នៃបដិវត្តន៍ខែសីហា និងទិវាបុណ្យជាតិនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណបក្សប្រជាជនកម្ពុជា បានបញ្ចប់ទស្សនកិច្ចប្រកបដោយលទ្ធផលផ្លែផ្កា ស្របជាមួយនឹងការចូលរួមខួបលើកទី៨០ នៃបដិវត្តន៍ខែសីហា និងទិវាបុណ្យឯករាជ្យជាតិនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលបានប្រព្រឹត្តទៅពីថ្ងៃទី១ ដល់ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២៥។ នៅក្នុងឱកាសទស្សនកិច្ចនេះ **សម្តេចតេជោ** បានជួបពិភាក្សាការងារទ្វេភាគីជាមួយថ្នាក់ដឹកនាំវៀតណាមមួយចំនួន រួមមាន ឯកឧត្តម **តូ ឡឹម** អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម ឯកឧត្តម **ជឹន ថាញ់ មិន** ប្រធានរដ្ឋសភា និងឯកឧត្តម **ផាម មិញជិញ** នាយករដ្ឋមន្ត្រី។

ក្នុងជំនួបខាងលើ ថ្នាក់ដឹកនាំវៀតណាមបានសម្តែងនូវការពេញចិត្ត និងស្វាគមន៍យ៉ាងកក់ក្តៅចំពោះ **សម្តេចតេជោ** ដែលបានដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា ចូលរួមពិធីប្រារព្ធទិវាជាប្រវត្តិសាស្ត្រដ៏សំខាន់ៗរបស់វៀតណាម។ នេះជាសក្ខីភាពនៃទំនាក់ទំនងជាប្រពៃណី សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធរវាងប្រទេសទាំងពីរ។ **សម្តេចតេជោ** បានសង្កត់ធ្ងន់ថា ព្រឹត្តិការណ៍ជ័យជម្នះជាប្រវត្តិសាស្ត្រអស់រយៈពេល ៨០ឆ្នាំមកនេះ មិនត្រឹមជាសមិទ្ធផលដ៏ធំធេងរបស់វៀតណាមប៉ុណ្ណោះទេ ប៉ុន្តែជាចលនាជំរុញមួយនៅក្នុងតំបន់ និងពិភពលោក ហើយការប្រកៀកស្មាគ្នាប្រឆាំងនឹងអាណានិគមរួម និងការជួយគ្នាទៅវិញទៅមក ក្នុងបុព្វហេតុរំដោះប្រទេសជាតិពីអាណានិគម ហើយបន្តគាំទ្រគ្នាទៅវិញទៅមកក្នុងការអភិវឌ្ឍជាតិ ឱ្យមានការរីកចម្រើនលើគ្រប់វិស័យរហូតដូចបច្ចុប្បន្ន សម្រាប់កម្ពុជា-វៀតណាម-ឡាវ ពិតជាគុណតម្លៃនៃសច្ចធម៌គួរជាទីមោទកៈ និងមិនអាចបំបាត់បាន និងដែលត្រូវបន្តពង្រឹង ថែរក្សា និងពូនជ្រុំបន្ថែមទៀត។

ថ្នាក់ដឹកនាំទាំងពីរបានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងដ៏ជិតស្និទ្ធ និងកិច្ចសហប្រតិបត្តិការដ៏ល្អប្រសើរលើគ្រប់វិស័យ និងគ្រប់កម្រិត ទាំងរវាងក្របខ័ណ្ឌនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ គណបក្ស និងរវាងប្រជាជននៃប្រទេសទាំងពីរ ដែលបានផ្តល់អត្ថប្រយោជន៍ជាក់ស្តែងដ៏ច្រើនលើសលប់។ ដោយឈរលើមូលដ្ឋាននៃការរីកចម្រើននេះ ភាគីទាំងពីរបានឯកភាពលើកកម្ពស់ទំនាក់ទំនងកម្ពុជា-វៀតណាម ឱ្យកាន់តែខ្ពស់មួយកម្រិតទៀត ស្របតាមស្មារតីនៃភាពជាអ្នកជិតខាងល្អ មិត្តភាពជាប្រពៃណី កិច្ចសហ-ប្រតិបត្តិការគ្រប់ជ្រុងជ្រោយ និងស្ថិរភាពយូរអង្វែង ដើម្បីសុខុមាលភាព និងវិបុលភាពយូរអង្វែងជូនប្រជាជន និងប្រទេសទាំងពីរ។

ថ្នាក់ដឹកនាំទាំងពីរបានយល់ស្របគ្នាថា ទំនាក់ទំនងរវាងបក្សនៃប្រទេសទាំងពីរពិតជាមានការរីកចម្រើនខ្លាំងក្លា និងកំពុងដើរតួនាទីជាប្រទីបបំភ្លឺ និងផែនទីចង្អុលផ្លូវសម្រាប់ការងាររដ្ឋ ក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការទ្វេភាគីឱ្យកាន់តែសកម្ម និងចំទិសដៅ។ ភាគីទាំងពីរបានឯកភាពជំរុញបន្ថែមទៀតនូវការផ្លាស់ប្តូរទស្សនកិច្ច និងការប្រាស្រ័យទាក់ទងគ្នាគ្រប់កម្រិតឱ្យកាន់តែញឹកញាប់ ដែលនេះជាផ្នែកមួយនៃការពង្រឹងការជឿទុកចិត្តផ្នែកនយោបាយដ៏ធំធេង និងជួយឱ្យកិច្ចសហប្រតិបត្តិការទ្វេភាគីកាន់តែស៊ីជម្រៅ និងមានផ្លែផ្កាច្រើន។ ភាគីទាំងពីរក៏បានប្តេជ្ញាបន្តប្រកាន់ខ្ជាប់គោលការណ៍មិនអនុញ្ញាតឱ្យកម្លាំងណាមួយមកបំបែកបំបាក់មិត្តភាពរបស់ប្រទេសទាំងពីរ ឬប្រើប្រាស់ទឹកដីរបស់ប្រទេសមួយប្រឆាំងនឹងប្រទេសមួយទៀតឡើយ និងរួមគ្នាប្រឆាំងនឹងបដិវត្តន៍ពណ៌ឱ្យបានដាច់ខាត។

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: secretariat@senate.gov.kh

ក្នុងការបន្តទាញយកប្រយោជន៍ពីសក្តានុពលនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចដែលបំពេញឱ្យគ្នាទៅវិញទៅមក ភាគីទាំងពីរបានឯកភាពបន្តជំរុញកំណើនទំហំពាណិជ្ជកម្មទ្វេទិស ឱ្យដល់គោលដៅ ២០ពាន់លានដុល្លារអាមេរិក នារយៈពេលប៉ុន្មានឆ្នាំដ៏ខ្លីខាងមុខនេះ ព្រមទាំងជំរុញក្រសួងនិងស្ថាប័នពាក់ព័ន្ធនៃប្រទេសទាំងពីរសហការឱ្យកាន់តែជិតស្និទ្ធ ដើម្បីសម្រេចឱ្យបានឆាប់នូវការងារអាទិភាពសំខាន់ៗ ដែលជាកុងសង់ស៊ីសរបស់ថ្នាក់ដឹកនាំទាំងពីរ រួមមាន ការរៀបចំសម្ពោធជាផ្លូវការនូវច្រកទ្វារអន្តរជាតិម៉ឺនជ័យ(ព្រៃវែង)-តឹនណាម(តៃនិញ) ក្រោមអធិបតីភាពនាយករដ្ឋមន្ត្រីទាំងពីរ និងការកំណត់ចំណុចតភ្ជាប់ផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងបាវិត និងហូជីមិញ-ម៉ុកបៃ។

ភាគីទាំងពីរក៏បានជំរុញកិច្ចសហការលើវិស័យគន្លឹះៗសម្រាប់ការកសាងសេដ្ឋកិច្ច-សង្គមនៃប្រទេសទាំងពីរ (កម្ពុជា វៀតណាម) ឱ្យកាន់តែទំនើប និងស៊ីវិល័យ រួមមាន ការពារជាតិ សន្តិសុខ វិនិយោគ ធុរកិច្ច ឧស្សាហកម្ម ទូរគមនាគមន៍ សុខាភិបាល អប់រំ ទេសចរណ៍ ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងការតភ្ជាប់រវាងប្រជាជននិងប្រជាជន ជាពិសេសរវាងយុវជន។

ក្នុងបរិបទនៃពិភពលោកពោរពេញដោយភាពប្រឈមខ្ពស់ ភាគីទាំងពីរបានផ្លាស់ប្តូរទស្សនៈគ្នាស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌពហុភាគី និងបញ្ហាតំបន់ដែលមានផលប្រយោជន៍និងជាកង្វល់រួម។ **សម្តេចតេជោ** បានគូសបញ្ជាក់នូវតួនាទីដ៏សំខាន់របស់អាស៊ាន ជាពិសេសប្រធានអាស៊ាន (ម៉ាឡេស៊ី) ជាមួយនឹងកិច្ចសហការរៀបចំដោយសហរដ្ឋអាមេរិក និងការចូលរួមយ៉ាងសកម្មពីសាធារណរដ្ឋប្រជាមានិតចិន ដែលសម្រេចបាននូវបទឈប់បាញ់ក្នុងជម្លោះព្រំដែនកម្ពុជា-ថៃ ក៏ដូចជាសារៈសំខាន់នៃការបង្កើតក្រុមអ្នកសង្កេតការណ៍អាស៊ានដ៏ចាំបាច់ ដើម្បីត្រួតពិនិត្យបទឈប់បាញ់ និងជួយដល់ការធ្វើឱ្យមានប្រក្រតីភាពឡើងវិញបានឆាប់។ ថ្នាក់ដឹកនាំវៀតណាមបានសម្តែងការគាំទ្រចំពោះបទឈប់បាញ់និងការសង្កេតការណ៍បទឈប់បាញ់ដែលមានប្រសិទ្ធភាព ហើយចង់ឃើញព្រំដែនកម្ពុជា-ថៃ ជាព្រំដែនសន្តិភាព និងមានភាពប្រក្រតីឡើងវិញ តាមរយៈការដោះស្រាយដោយសន្តិវិធី តាមការចរចា ការទូត និងស្របតាមច្បាប់អន្តរជាតិ។

ក្នុងឱកាសកម្មវិធីផ្លូវការដ៏មមាញឹកនៅទីក្រុងហាណូយ **សម្តេចតេជោ**ក៏បានអញ្ជើញចូលរួមពិសាអាហារថ្ងៃត្រង់គណបក្សទាំងបី កម្ពុជា-វៀតណាម-ឡាវ រួមមាន ឯកឧត្តម **តូ ឡឹម** អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម **សម្តេចតេជោ ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជា និងឯកឧត្តម **ថង លុនស៊ីសុលីត** អគ្គលេខាធិការបក្សប្រជាជនបដិវត្តន៍ឡាវ ប្រកបដោយមិត្តភាព ភាតរភាព និងស្និទ្ធស្នាលជាទីបំផុត។ ថ្នាក់ដឹកនាំគណបក្សទាំងបីឯកភាពបន្តពង្រឹងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងគណបក្សទាំងបី ឱ្យកាន់តែស្អិតល្មួត និងស៊ីជម្រៅ និងគាំទ្ររដ្ឋាភិបាលនៃប្រទេសទាំងបី ក្នុងការងារកសាង និងអភិវឌ្ឍន៍ប្រទេសឱ្យសម្រេចបាននូវគោលដៅយុទ្ធសាស្ត្ររៀងៗខ្លួន។ **សម្តេចតេជោ** បានបង្ហាញពីការត្រៀមខ្លួនរបស់កម្ពុជា ក្នុងរៀបចំកិច្ចប្រជុំកំពូលប្រចាំឆ្នាំរវាងគណបក្សទាំងពីរកម្ពុជា-វៀតណាម និងកិច្ចប្រជុំកំពូលរវាងគណបក្សទាំងបី កម្ពុជា-វៀតណាម-ឡាវ នៅរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា តាមការគ្រោងទុក។

ទស្សនកិច្ចលើកទី៣ នៅក្នុងឆ្នាំ២០២៥ របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងនាមជាប្រធានព្រឹទ្ធសភា និងជាប្រធានគណបក្សប្រជាជនកម្ពុជា នៅសាធារណរដ្ឋសង្គមនិយមវៀតណាម នាពេលនេះ ជាការបញ្ជាក់ច្បាស់នូវភាពរឹងមាំស្ថិតស្ថេរនៃទំនាក់ទំនងកម្ពុជា-វៀតណាម ក្នុងដំណើររួមគ្នាបន្តជំរុញកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី ដើម្បីនាំមកនូវសមិទ្ធផលរួម និងរួមចំណែកសន្តិភាព ស្ថិរភាព និងវិបុលភាពក្នុងតំបន់ និងពិភពលោក៕

ថ្ងៃអង្គារ ១០កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២៥